គេស្ងប់ស្ងាត់! ស្ងប់ស្ងាត់សឹងថា គេស្តាប់មិនឮ និងមើលមិនឃើញអ្វីៗនៅជុំវិញខ្លួនទាំងអស់ ទាំងដែលគេកំពុងតែបើកភ្នែកសម្លឹងនិងផ្ទៀងត្រចៀកក្តី។

សួរថា ហេតុអ្វីបានជាខ្ញុំកត់សម្គាល់គេ?

នៅថ្ងៃដែលយើងចួបគ្នាដំបូង គេឈឺពោះហើយមិនស្គាល់សូម្បីតែប្រេងកូឡាថាជាអ្វី។

ឃើញទឹកមុខនិងអាកប្បកិរិយាប្លែកៗរបស់គេ ខុសពីក្មេងស្រីទូទៅ សម្តីសំដៅរបស់គេខ្ញុំអាចកាត់យល់ពីព្រោះខ្ញុំជាមនុស្សម្នាក់ដែលធ្លាប់ឆ្លងកាត់ដំណើរការបែបនេះ គឺដំណាក់កាលដែលជីវិតយើងសាបឈឹង ឥតរសជាតិ គ្មានតម្លៃ គ្មានន័យហើយមិនដឹងថាមានថ្ងៃស្អែក ធ្វើអ្វីផង។

ជាការពិត យើងពិបាកនៅក្នុងការចួបមនុស្សម្នាក់ដែលចិត្តយើងអន្ទះសាចង់ដឹងអំពីគេហើយក៏ពិបាកនៅក្នុងការផ្សារភ្ជាប់ទំនាក់ទំនងដែលគ្មានការសន្ទនាច្រើន ប៉ុន្តែនិស្ស័យអ្វីមួយពិតជាសំខាន់បានតភ្ជាប់គម្លាតរបស់យើងទាំងពីរ។

គេឈ្មោះពៅ គេធ្វើការនៅហាងខោអាវប្រេនមួយ។

គេស្លៀកពាក់ស្អាតបាត មើលមួយភ្លែតអាចគិតថាជាកូនស្រីអ្នកមានទ្រព្យសម្បត្តិ កាយវិការគេថ្លៃថ្នូរ គេស្លូត មិនចេះនិយាយច្រើននិងត្រូវថៅកែធ្វើបាបប្រើគេខុសបែបបទហួសម៉ោងហួសពេលនៅហាងអនឡាញនោះ ដូច្នេះហើយគេអត់ប្រើទូរសព្ទ។

នេះក៏ប្រហែលជាមូលហេតុដែលគេនៅឆ្ងាយពីសង្គមនិងមានចរិតចម្លែក តែជាចរិតចម្លែកដែលខ្ញុំពិតជាចង់ដឹង។

និស្ស័យមួយនេះពិតជារឹងមាំនិងប្រើពេលវេលាដ៏សែនខ្លី យើងក៏យល់ចិត្តគ្នា។ នៅថ្ងៃមួយដែលយើងរកឃើញអ្នកណាម្នាក់ថាជាស្នេហាពិត គួរឱ្យចង់ការពារ គួរឱ្យចង់ប្រើជីវិតរួមគ្នាខ្ញុំក៏សម្រេចចិត្តសារភាព ប្រាប់គេអំពីអតីតកាលរបស់ខ្លួនឯងដែលខ្ញុំស្អប់និងអាម៉ាស់។

«ខ្ញុំធ្លាប់ជាប់គុក! ខ្ញុំមិនស្អាតស្អំ មិនអាចធ្វើលិខិតថ្កោលទោសដូចគេឯងបានទេពៅ! ប្រុសម្នាក់នៅចំពោះមុខពៅ មានសាវតារមិនល្អទេ!»

ឮហើយគេនៅស្ងៀមគ្មានពាក្យសូម្បីមួយម៉ាត់ណា។ នៅពេលដែលខ្ញុំសម្រេចចិត្តប្រើសេចក្តីក្លាហាន យករឿងមិនសប្បាយចិត្តបំផុតនៃជីវិតមកប្រាប់គេ គឺខ្ញុំចង់វិនិយោគភាពស្មោះ

ឱ្យគ្នា ហើយ....ខ្ញុំក៏ត្រៀមខ្លួនជាស្រេចក្នុងការ.....ដើរចេញ....ទាំងមិនបន្ទោសអ្វីទាំងអស់ ប្រសិនខាងស្រីមិនអាចទទួលយកខ្ញុំបាន។

ពេលនោះហើយ....គេមិនបាច់ហើបមាត់តែខ្ញុំត្រូវដឹងខ្លួន....ខ្ញុំក្រោកចាកចេញ..... ស្រាប់តែ...

«ឈប់! ឌី! ឈប់! ខ្ញុំមិនបានគិតអាក្រក់ ឬអន់ចិត្តអីពីអតីតកាលរបស់វណ្ណឌីទេ!»

«មិនមែនកំហុសរបស់ពៅទេ! គ្រាន់តែខ្ញុំយល់ថា គ្រួសារពៅប្រហែលជាមិនអាចទទួលយកខ្ញុំបាន!»

«ទេមិនមែនទេ! មិនទាក់ទងនឹងអ្នកណាទាំងអស់!»

«តាមពិតមុននេះចង់ប្រាប់ឌីថា....គឺខ្ញុំខ្លួនឯង ក៏មានអតីតកាល! រឿងដែលយ៉ាប់មកពីខ្ញុំកំសាក គឺខ្ញុំមិនអាចនិយាយចេញមកដូចឌី!»

«ទោះជាពៅពីមុនមកបានឆ្លងកាត់អ្វីខ្លះ ខ្ញុំទទួលយកពៅបានទាំងអស់!»

ពេលខ្ញុំស្រឡាញ់ស្រី ខ្ញុំគិតជានិច្ចថា នឹងចែករំលែកគ្រប់យ៉ាងជាមួយគេ អត់ចង់លាក់អ្វីជាមួយគេទេ ព្រោះក្នុងមួយជីវិតនេះ ខ្ញុំស្អប់មនុស្សដែលលាក់គំនួច រឿងនេះនឹងនាំទៅដល់ការក្បត់គ្នា។

មនុស្សដែលស្ងប់ស្ងាត់ ស្លូតបូត ឃើតយ៉ាវតែស្មោះត្រង់ គេជាមនុស្សដែលខ្ញុំចង់បានបំផុត ហើយក៏មិនដែលស្ដាយក្រោយក្នុងការសារភាពចំណុចអាក្រក់ប្រាប់នាងដែរ ព្រោះខ្ញុំយល់ថា បានធ្វើអ្វីមួយដែលមនុស្សស្រឡាញ់គ្នាគប្បីត្រូវធ្វើ។

ខ្ញុំឈ្មោះវណ្ណឌី ហើយខ្ញុំកំពុងតែសប្បាយចិត្តនឹងជីវិតមួយនេះដោយសារមានគេបង្ហាញខ្លួន។ ជីវិតកន្លងមកដែលចាប់ផ្តើមដោយបញ្ហាក្នុងគ្រួសារ និងវិថីយុវវ័យដែលពេលខ្លះងងឹតខ្លាំង បានចាប់មានពន្លឺឡើងវិញនៅពេលមនុស្សដែលយើងស្រឡាញ់បង្ហាញខ្លួន។

«ខ្ញុំជាមនុស្សចូលចិត្តទឹក បើសិនជាយើងមានផ្ទះមួយ មានកូនពីរនាក់ យើងនាំគេមកលេងក្បែរទឹកបឹង ខ្ញុំនឹងបង្រៀនកូនៗយើងហែលទឹក!»

គេញញឹម។ នេះជាពេលវេលាដែលយើងសប្បាយចិត្តព្រោះខ្ញុំកំពុងផ្ដើមការងារតូចមួយ គឺឌីហ្សាញអនឡាញ។ ខ្ញុំទទួលបាននូវភ្ញៀវដំបូងម្នាក់ ដែលបញ្ជាទិញសេវាកម្មកុងត្រាមួយឆ្នាំ ជាអ្វីដែលខ្ញុំនិងគេពិតជារីករាយខ្លាំង។

នៅពេលដែលគេចុះងូតទឹក ខ្ញុំសួរគេថា គេគិតយ៉ាងណារឿងគ្រួសារតូចរបស់យើង គេក៏ញញឹមឆ្លើយមកខ្ញុំថា៖

«បេះដូងនេះកំពុងបែងចែកជាបី ហើយចតនីមួយៗដ៏កក់ក្ដៅខ្លាំងណាស់ សម្រាប់ក្មេងពីរនាក់ ហើយនិងមនុស្សប្រុសម្នាក់ដូចជាឪ!»

ចំណែកខ្ញុំវិញ ខ្ញុំប្រាប់គេថា៖

«បងគ្មានបេះដូងទេ! បេះដូងបងឱ្យទៅពៅទុកអស់ហើយ! ស្អីក៏ដោយ ក៏ជារបស់ពៅដែរ!»

គេនៅធ្មឹងមុនដំបូងពេលឮពាក្យពេចន៍ស្នេហានេះ ក្រោយមកគេទម្លាក់ទឹកមុខ ដូច្នេះហើយខ្ញុំក៏ខ្សឹបបញ្ជាក់ជាមួយគេ៖

«អត់ជឿ? បងជាមនុស្សស្រឡាញ់ភាពស្មោះត្រង់ហើយស្អប់អំពើផិតក្បត់ អ៊ីចឹងទោះបីឥឡូវបងគ្មានអ្វីជាការសន្យា តែបេះដូងស្មោះត្រង់មួយនេះ បងមិនយកវាវិញទេ ជូនអូនរហូត!»

គេងាកមុខចេញនិងទៅជាគេចៗពីខ្ញុំ។ មិនយល់ដែរថា ហេតុអីក៏ភាពស្មោះត្រង់ធ្វើឱ្យគេពិបាកទទួលយកម្ល៉េះ។ អារម្មណ៍ដែលថាគេគ្មានសុវត្ថិភាពផ្លូវចិត្ត ហាក់មានកាយវិការរងសម្ពាធ គឺជាអារម្មណ៍ដែលផ្សារភ្ជាប់មកខ្ញុំភ្លាមៗគ្រានោះ ដ្បិតរាល់ពេលនៅក្បែរគ្នា ឱ្យតែពៅលែងស្រស់ស្រាយ ឬក៏មានអ្វីម្យ៉ាងកំពុងតែធ្វើទុក្ខនៅក្នុងបេះដូងរបស់គេ ខ្ញុំទទួលអារម្មណ៍ដឹងភ្លាម ដូចចរន្តអគ្គិសនីឆ្លង។

«កើតអី?» ខ្ញុំខ្សឹបសួរគេ ហើយពិតជាចង់ឱបត្រកងគេណាស់។ មានអ្វីពិបាកចិត្តជាងឃើញទេពធីតាស្រពោន។ ចរិតគេ មិនសមថាគេរើសអើងសភាពបច្ចុប្បន្នអត់លុយអត់កាក់របស់ខ្ញុំទេ តែគេដូចជាមានរឿងច្រើនទៀតមិននិយាយចេញមក មនុស្សមិនងាយមាត់ដូចគេ។

«មនុស្សស្រឡាញ់គ្នា មានទុក្ខត្រូវចែករំលែកគ្នា!»

គេឮពាក្យនេះទៀតចេញពីមាត់ខ្ញុំ ក៏បែរមកកាន់ដៃខ្ញុំដោយភ្នែកស្រងូត។ ដោយឃើញខ្ញុំនៅរង់ចាំស្ដាប់គេក៏ដាច់ចិត្តនិយាយ៖

«មានខ្លះ! តែជិតដោះស្រាយចប់ហើយ!»

ព្រោះគេដូចជាមិនចង់និយាយ ខ្ញុំក៏មិនចង់ដេញដោលខ្លាចគេកាន់តែពិបាកចិត្ត។ ម្ល៉ោះហើយខ្ញុំប្តូរបរិយាកាស ស្ងប់ស្ងាត់នេះចេញ ....ពេលគេបែរខ្នងគេចមុខ ខ្ញុំលួងគេថា៖

«មានរឿងអីក៏ដោយ ចាំថា...បងស្រឡាញ់អូន! យើងនឹងរៀបការជាមួយគ្នា!»

គេងាកមកវិញចំពេលដែលខ្ញុំខ្សឹប ដូច្នេះហើយចៃដន់មាត់របស់យើងប៉ះគ្នាក្នុងទឹក។ ខ្ញុំមិនដែលមានគំនិតចង់ខ្សែលើរឿងមួយ ឬធ្វើអ្វីផ្តេសផ្តាសដាក់គេដូចជាក្មេងជំទង់ក្នុងរបត់ទំនើបនោះទេ។ ក្នុងជម្រៅបេះដូងនេះ ខ្ញុំតែងតែចង់ឱ្យគេជាមនុស្សស្រីដ៏ល្អម្នាក់បែបនេះ រហូតដល់ថ្ងៃយើងក្លាយជាប្តីប្រពន្ធនឹងគ្នា គេជាបុប្ផាក្រពុំ ខ្ញុំមិនចង់ក្តិចទម្លាក់មុនពេលខ្ញុំមានថូទឹកមកថែទាំគេបានត្រឹមត្រូវនោះទេ។

ដូច្នេះហើយនេះគឺជាការថើបដោយឆក់កណ្តៀតមួយ ដែលបេះដូងលោតញាប់ញ័របំផុតនៅក្នុងជីវិតខ្ញុំ។ គេញញឹមស្រស់ស្រាយឡើងវិញក្រោយហេតុការណ៍នោះ តែគេមិនដឹងថាស្នាមញញឹមរបស់គេនាំមកឱ្យខ្ញុំនូវភាពកក់ក្តៅកម្រិតណាទេ។

ប្រសិនបើគេមានអារម្មណ៍ថា មានសុវត្ថិភាពពេលនៅក្បែរខ្ញុំ ឬត្រៀមទទួលយកខ្ញុំចូលទៅក្នុងជីវិតរបស់គេ ជាការលើកទឹកចិត្តមួយធំធេង ឱ្យខ្ញុំបានយល់ពីអត្ថន័យជីវិតឡើងវិញ នៅក្រោយពេលដែលខ្ញុំបានដើរចេញពីពន្ធនាគារ ហើយធ្លាប់គិតថាជាតិនេះប្រហែលជាគ្មាននរណាម្នាក់ព្រមទទួលយកខ្ញុំជាខ្ញុំបែបនេះទេ។ ណាមួយទៀត សាវតាមួយនេះ ខ្ញុំគិតថាមិនអាចរកបានមនុស្សស្រីដែលមានអាកប្បកិរិយាថ្លៃថ្នូរដូចជាពៅនោះងាយដែរ។ សរុបមកវិញវត្តមានរបស់គេគឺជាថ្នាំទិព្វ ផ្តល់មកឱ្យជីវិតមួយដែលឆ្លងកាត់លួសបន្លា ខ្នោះដៃនិងរឿងឈឺចាប់ជាច្រើនទៀតតាំងពីកុមារមក រស់ឡើងវិញដូចដប់។

ទោះយ៉ាងណា យប់នេះប្លែកពីរាល់ដង ខ្ញុំទាក់ទងគេមិនបាន។ យើងមិនដែលខាននិយាយគ្នា ឬឈែតរកគ្នាទេ។

ចម្លែក!

«បងខលរកអូនច្រើនដងហើយពៅ! ចង់ប្រាប់ថា ស្អែកនេះបងទៅស៊ីញ៉េកុងត្រាយកលុយកក់ពីគេហើយ!»

ស្ងាត់!

គេមានរឿងអីបានជាមិនអនឡាញ?

ខ្ញុំអន្ទះសា។

នៅពេលដែលយើងស្រឡាញ់អ្នកណាម្នាក់ យើងចាប់ផ្ដើមចង់ដឹងគ្រប់វិនាទីនីមួយៗដែលកំពុងអូសរំលងទៅ នៅខាងគេ តើគេកំពុងធ្វើអ្វី?សង្កេតឃើញអំពីភាពស្ងប់ស្ងៀមរបស់គេធ្វើឱ្យខ្ញុំបារម្ភ។

គេខឹងខ្ញុំរឿងពីព្រឹកនៅក្នុងបឹងឬយ៉ាងណា?

ខ្ញុំមានសំណួរជាច្រើនសម្រាប់ខ្លួនឯង។

ខ្ញុំគិតខ្វល់ខ្វាយរហូតដល់លង់លក់ទាំងចិត្តនេះមិនស្ងប់ទេ។ ពេញមួយរាត្រីខ្ញុំសុបិនឃើញរឿងមួយចំនួនដែលទ្រូងខ្ញុំខ្លួនឯងហាក់មានការបារម្ភខ្វល់ខ្វាយ។

រឿងមួយដែលធំ និងដែលខ្ញុំបារម្ភបំផុតនៅពេលនេះ គឺខ្ញុំត្រូវឃ្លាតឆ្ងាយពីមនុស្សដែលខ្ញុំស្រឡាញ់បំផុត។ ខ្ញុំជាក្មេងគ្មានម្ដាយតាំងពីតូច រឿងកម្មក្នុងជីវិតបានឆក់យកមនុស្សស្រីម្នាក់ដែលខ្ញុំស្រឡាញ់ដំបូងគេឱ្យចាកចោលខ្ញុំ តែខ្ញុំនៅតែនឹកគាត់ជាខ្លាំង។ តែឥឡូវនេះ ក្ដីបារម្ភនោះនៅតែបន្តតាមប្រាណដោយសារខ្ញុំចេះស្រឡាញ់មនុស្សស្រីម្នាក់ទៀតហើយ រហូតដល់ខ្ញុំភ្លេចមនុស្សស្រីដំបូងដែលបានសម្លាប់ជីវិតកុមារភាពនិងយុវវ័យរបស់ខ្ញុំ។

ព្រលឹមកាលណាខ្ញុំចុចបើកទូរសព្ទមើលគេផ្ញើសារតបមកដោយស្នាមញញឹមហើយឆ្លើយខ្លីថា៖

«អរុណសួស្ដី! ប៉ុន្តែខ្ញុំរវល់បន្តិចថ្ងៃនេះ ដោះស្រាយរឿងចប់ យើងនិយាយជាមួយគ្នាទៀតណ៎ា!»

ហើយក៏បាត់គេពីអនឡាញទៅ។

គេមិនបានប្រាប់នៅឡើយថា យប់មិញមានធុរៈអ្វី ប៉ុន្តែគ្រាន់សម្ដីប៉ុន្មានម៉ាត់នេះ ក៏ធ្វើឱ្យបេះដូងកក់ក្ដៅរួចទៅហើយ គេមិនសូវលេងទូរសព្ទទេ ខ្ញុំត្រូវទទួលស្គាល់រឿងនេះ។

រៀបចំខ្លួនយ៉ាងមោទនភាពជាមួយនឹងរូបរាងថ្មីសន្លឹមៗនៃជីវិតមួយដែលពេញដោយសុភមង្គល។ អាជីពនិងមនុស្សយល់ចិត្ត ពីរយ៉ាងនេះគ្រប់ហើយសម្រាប់មនុស្សដូចខ្ញុំ។

ខ្ញុំព្រឹកនេះតាំងចិត្តទាត់ចោលគ្រប់អ្វីដែលខ្ញុំបានឆ្លងកាត់។ ទុក្ខព្រួយនិងវិញ្ញាសារពិឃាតទាំងប៉ុន្មានរបស់ខ្ញុំ រាប់ចាប់តាំងពីគ្រួសារដែលបាក់បែក យុវវ័យដែលពេញដោយហិង្សាគ្មានការអប់រំ ការរស់នៅក្នុងពន្ធនាគារ ហើយចុងក្រោយខ្ញុំបានផ្លាស់ប្តូរខ្លួនឯងមកក្លាយជាមនុស្សម្នាក់ដែលមានជីវិតប្រសើរឡើងវិញ។

«សួស្តីខ្ញុំឈ្មោះវណ្ណឌី ខ្ញុំមកកុងត្រាខាងឌីហ្សាញបង!»

«បាទ សូមអញ្ជើញអង្គុយសិន! ខ្ញុំជូនដំណឹងទៅផ្នែកProjects»

«បាទ សូមអរគុណបង!»

ចេញពីការងារចុះកិច្ចព្រមព្រៀង ខ្ញុំបានទូរសព្ទទៅគេទៀតនៅតែមិនចូល។ ខ្ញុំត្រូវការអ្នកណាម្នាក់ចែករំលែកសុភមង្គលនេះ ម្ល៉ោះហើយខ្ញុំខលជម្រាបប៉ាខ្ញុំ។

«ហើយក្រែងពីមុនថា មិនចង់ធ្វើអ្នកឌីហ្សាញ ចង់ធ្វើជាអ្នកកាន់ Creative?» ប៉ាជាន់កែងខ្ញុំព្រោះដឹងរឿងថាខ្ញុំចង់បានប្រពន្ធឡើងញ័រខ្លួន ខំរកលុយ ស្អីក៏ធ្វើថែមទាំងជម្រុះឬកពារើស projects ដែលគាត់ធ្លាប់ដឹងមក។

«តែឥឡូវនេះផ្សេងប៉ា...ខ្ញុំប្រញាប់ រកលុយដណ្តឹងកូនគេ!»

ហើយ....រឿងសម្រេចចិត្តមានគូស្រករនេះ វាមិនសាមញ្ញដូចដែលយើងធ្លាប់ឃើញនៅក្នុងកុនទេ ប៉ុន្តែអត្ថន័យស្នេហាខ្ញុំដឹងថា ពិតជាបានផ្លាស់ប្តូរពីសភាពមនុស្សម្នាក់ទៅមនុស្សម្នាក់ផ្សេងមែន ខ្ញុំព្រមធ្វើអ្វីមួយដែលខ្ញុំមិនគិតថា ចង់ធ្វើពីមុនមក ហើយទទួលយកនូវអ្វីមួយដែលខ្ញុំធ្លាប់តែមិនយល់ព្រម។

ចប់ពីប៉ា ខ្ញុំដើរមកដល់ក្បែរម៉ូតូ។ ពីចំហៀងខ្ញុំបានឃើញមនុស្សប្រុសពីរនាក់ឈរសម្លឹងមក គិតថាគេសម្លឹងមកប្រភពនេះ ប៉ុន្តែមិនមែនសំដៅខ្ញុំទៅចុះព្រោះខ្ញុំមិនដែលស្គាល់ពួកគេទេ។

ស្រាប់តែមនុស្សម្នាក់ទីបីម្នាក់បង្ហាញខ្លួន។

នៅពេលដែលខ្ញុំឱនចាក់សោ ជននោះត្រូវសូហ្វ័របើកទ្វារអញ្ជើញឱ្យចុះពីលើឡានទំនើប។ ខ្ញុំពិតជាមានអារម្មណ៍ស្រដៀង ដូចធ្លាប់ឃើញគេ ប្រហែលជាសហគ្រិនជោគជ័យដែលមានរូបថតជាច្រើននៅក្នុងទស្សនាវដ្តីអនឡាញ ក្នុងផ្នែកតិចណូឡូជីដែលខ្ញុំស្រឡាញ់។

ខ្ញុំព្យាយាមងាកទៅសម្លឹងគេជាមួយញញឹម។

ជាមួយនឹងទឹកមុខស្រស់សង្ហានិងដំណើរឡូយឆាយដែលគេដើរមកដូចជាសំដៅរកខ្ញុំ?..... តើមានរឿងល្អអីទៀតកើតមានឡើងក្នុងថ្ងៃនេះ?

«ប្អូនឈ្មោះវណ្ណឌី?»

«បាទ....ខ្ញុំ!»

ខ្ញុំមួលសោទុកវិញ ព្រោះមិនដឹងថាតើគេនេះមានការអ្វី ហើយហេតុអ្វីស្កាត់មកចួបខ្ញុំនៅទីនេះ?

ណាមួយក្រឡេកទៅឃើញអ្នកទាំងពីរដែលមកដល់មុនធ្វើមុខស្មើ ដូចជាទុកខ្ញុំមិនស្មើពួកគេ? អាការៈទំនងជាដៃជើង ឬកងកាពារតាមហែហមអ្នកមានម្នាក់នេះ?

បុរសនោះដើរមកដល់គេញញឹម លើកអេក្រង់ទូរសព្ទហើយបង្ហាញខ្ញុំ។

«មនុស្សស្រីម្នាក់នេះ....ស្គាល់ទេ?»

ខ្ញុំសម្លឹងមុខគេឆ្ងល់ រួចរេភ្នែកទៅផ្ទង់លើទូរសព្ទគេទាំងអារម្មណ៍ពិភាល់។

ពៅ?

អ្វីមួយប្រាប់ខ្ញុំក្នុងបេះដូងភ្លាមៗថា ម្នាក់នេះអាចតាមស្រឡាញ់ពៅ ឬអាចជាអតីតសង្សារពីមុនរបស់នាង ឬអាចជាអ្នកណាម្នាក់ដែលពាក់ព័ន្ធជាមួយនាង បានជាថ្ងៃនេះហ៊ានស្កាត់មករករឿងខ្ញុំ។

ខ្ញុំសម្រួលទឹកមុខស្មើ....ហើយងើបមុខមកសម្លឹងជននេះតបវិញដោយអាការៈខែងរ៉ែង។

«សួរមានន័យថាម៉េច?! ពៅសង្សារខ្ញុំ!»

វាជាអ្វីដែលមនុស្សប្រុសម្នាក់ត្រូវតែឆ្លើយ ពីព្រោះវាជាការពិត ហើយមិនត្រឹមតែសង្សារទេ ខ្ញុំមានគម្រោងវែងឆ្ងាយទៀតជាមួយគេ ដូច្នេះខ្ញុំមានអីត្រូវខ្លាចនៅក្នុងការប្រឈមមុខជាមួយមនុស្សទាំងអស់នេះ?

«ហើយមានការអីដែរ?»

ខ្ញុំច្រត់ចង្កេះសួរបន្ថែម អត់សប្បាយចិត្ត។

ជននោះធ្វើមុខស្មើ ដូចសុភាពបុរសសហគ្រិនជោគជ័យ ហើយចាប់ផ្ដើមចុចអេក្រង់បង្ហាញរូបថតពីរទៀត។ នាងនិងគេ.....? ឈុតរៀបការ!

....គាំង....ចងចិញ្ចើម....ខ្ញុំមើលងាកៗព្រោះមិនអស់ចិត្ត។

សំឡេងបុរសអ្នកមាននិយាយមកមួយៗ៖

«គេរៀបការរួចយូរហើយ! រៀបការជាមួយខ្ញុំ!.....ខ្ញុំជាប្ដីរបស់គេ!»

ខ្ញុំមិនដែលត្រូវរន្ទះបាញ់ទេ តែសភាពខ្ញុំពេលនេះមិនខុសពីនៅកណ្ដាលវាលឱ្យរន្ទះសម្លាប់។ ខ្ញុំនៅស្ងៀមដូចឆក់ជាប់ឆ្កឹងលើព្រះធរណី ស្ពឹកអស់ដៃជើង សម្លឹងអេក្រង់រហូតដល់ខាងគេចុចបិទ។

«ប្រុសប្អូន!»

គេដោយវាយស្មាខ្ញុំប៉ូក ធ្វើឱ្យខ្ញុំភ្ញាក់ពីភាំងហើយរលាស់ស្មាងាកទាំងខឹងសម្បា។

សំឡេងជននេះនិយាយមកមួយៗ៖

«ស្រីក្រមុំនៅមានច្រើនណាស់ មិនចាំបាច់សាកល្បងជាមួយនឹងទោសឯកពន្ធភាព ឬមួយក៏ធ្វើឱ្យភាគីផ្សេងៗ មានបញ្ហាជាមួយទេ! ឈប់ទាក់ទងប្រពន្ធខ្ញុំ! នេះជាការព្រមានទីមួយនិងជាចុងក្រោយបង្អស់!» ខ្ញុំងើបមុខសម្លឹងអ្នកដែលនិយាយជាមួយខ្ញុំដែលគេកំពុងធ្វើមុខមាំ។ ប្រសិនរឿងនេះជាការពិត ស្វាមីភាគច្រើននៅក្នុងប្រទេសយើងច្បាស់ជាឱ្យខ្ញុំធីពីរកណ្ដាប់ដៃហើយ ចំណែកគេនេះនៅសម្លឹងខ្ញុំធ្វើមុខស្មើឌីៗ។

បើសិនជាពៅពិតជាប្រពន្ធរបស់គេ ហេតុអីនាងមករកខ្ញុំ?

នៅពេលដែលខ្ញុំនៅស្ងៀមចំហមាត់គិត ដូចជាទទួលយកការពិតនេះមិនបាន បុរសដដែលនិយាយបន្ថែម៖

«ចាំស្ដាប់!»

ដោយដៃគេចាប់ផ្ដើមចុចទូរសព្ទ មាត់គេប្រាប់មកខ្ញុំបន្ថែម៖

«ហើយ...គេមិនមែនឈ្មោះពៅទេ...គេឈ្មោះរីដា!»

មិនយូរទេ មានអ្នកចុចទទួល គេបើកSpeakerនិយាយ៖

«នៅឯណាអូន?»

«នៅOffice!»

«បងទៅទទួល!»

«មិនបាច់ទេ! ខ្ញុំហៅពូ....»

«សូហ្វ័រចោលម្សៀតរបស់អូនឯងបងដេញចោលហើយ!»

រឿងដេញអ្នកណា អ្នកណាឈប់ អ្នកណានៅ ខ្ញុំមិនខ្វល់ ដឹងតែជាសំឡេងមនុស្សដែលខ្ញុំស្រឡាញ់១០០ភាគរយ។ លោកនេះម៉េចនឹងចួនគ្នាទាំងរូបរាងទាំងសំឡេង គ្រាន់តែឈ្មោះខុសគ្នា? សំឡេងមនុស្សស្រីដដែលឆ្លើយឡើងធ្វើឱ្យខ្ញុំសឹងតែប្រេះបែកដើមទ្រូង៖

«បងឯងគ្មានសិទ្ធិដេញគាត់ទេ!»

ជននេះឆ្លើយវិញ៖

«បងដឹកអូនឃ្វាលអូនម្ដៃប្អូនម៉ោងរីដា! ក្នុងនាម....ជាប្ដី!»

ជននោះបិទទូរសព្ទ ប្រុងនិយាយអ្វីនឹងខ្ញុំទៀត តែខ្ញុំដើរចេញ៖

«សង្សារខ្ញុំឈ្មោះពៅ មិនមែនរីដាប្រពន្ធបងឯងទេ! នៅផ្ទះមើលប្រពន្ធឱ្យជាប់ទៅ កុំដើរផ្អើលដាក់គេ!»

មនុស្សម្នាក់ដែលនៅចំហៀងខាងខ្ញុំ ស្ទុះមកដូចប្រុងក្រៀកឃាត់ខ្ញុំ ប៉ុន្តែខ្ញុំត្រៀមលក្ខណៈជាស្រេចក្នុងការទប់ទល់ជាមួយជននេះ ស្រាប់តែថៅកែរបស់គេរាដៃធ្វើជាសុភាពបុរស។

«មិនបាច់បារម្ភទេ! ចង់ដឹងពៅឬរីដា ហ៊ានទេ? ទៅមើលជាមួយគ្នាក៏បាន!»

ខ្ញុំហ៊ានទេ? ខ្ញុំសួរឯង!

តើត្រូវត្រលប់ទៅដេកឱបខ្នើយពិបាកចិត្ត សង្ស័យ ឬទៅជាមួយគ្នា បញ្ជាក់គ្រប់យ៉ាងពេលនេះ?

«មនុស្សដូចខ្ញុំគ្មានរឿងអីត្រូវខ្លាចនោះទេ!»

ការពិតខ្ញុំត្រូវតែប្រឈមមែន ខ្ញុំជិះម៉ូតូតាមពីក្រោយពួកគេរហូតដល់ក្រុមហ៊ុនធំមួយ។ ទីបំផុតទៅប្ដីគេបើកទ្វារចុះ ខ្ញុំនៅពីចម្ងាយក៏ឃើញគេចេញពីក្នុងមកជាមួយនឹងឈុតអភិជនយ៉ាងប្រណីត មាននារីជំនួយការកាន់កាបូបមកឱ្យទៀត។

ពៅធ្វើមុខស្រពោននៅចំពោះមុខជននេះ ប៉ុន្តែគ្រប់យ៉ាងជានាង។ មនុស្សដែលយើងស្រឡាញ់ ត្រឹមសក់មួយសរសៃក៏យើងស្គាល់បាន។

ប្ដីរបស់នាងឱបចង្កេះបណ្ដើរនាងឡើងឡាន ទាំងលបដៀងមកញញឹមសម្លឹងឌឺខ្ញុំ ចំណែកខ្ញុំសឹងតែស្រក់ឈាម បំពង់កណែន ដៃជើងជាប់ការស្ទិត។

ហេតុអ្វី? ខ្ញុំខឹងខ្លួនឯង!

ភាពក្លាហាននានាបាត់ទៅណាអស់?

ឡានពួកគេចាកចេញសន្សឹមៗ ម៉េចខ្ញុំមិនប្រឈមមុខឱ្យនាងឃើញហើយសួរច្បាស់ៗថា ពៅឬរីដា?

ប្ដីគេនាំគេចេញបាត់ហើយ....ផែនដីនេះពិតជាកំពុងក្រឡាប់ចាក់និងកប់លុបរាងកាយខ្ញុំ។

នាងពិតជាមនុស្សស្រីមកពីសង្គមជាន់ខ្ពស់ របៀបនិយាយស្ដី ស្លៀកពាក់ និងចុងក្រោយអ្វីៗដែលខ្ញុំឃើញនេះ....ប្ដីរបស់គេផ្ញើសារមក....ខ្ញុំឮសំឡេងទីតក៏ស្រែកម្នាក់ឯងថា «ពៅ!»... តែមិនមែនគេទេ...មនុស្សប្រុសនោះស្គាល់សូម្បីតែលេខដៃខ្ញុំ?

ពិភពលោកនេះក្រោមបាតដៃគេគេចង់ធ្វើអីខ្ញុំពេលណាក៏បាន...តែសម្ដីដែលផ្ញើមកនេះ វាឈឺជាងកណ្ដាប់ដៃទៅទៀត....«អាប្អូនកម្សត់! ទោះប្រពន្ធអញមិនទាន់រៀបការឬទំនេរក៏សម្បត្តិឯងនឹងគេ មេឃហើយនិងដី!!! គ្មានថ្ងៃចូលគ្នាចុះទេ! ក្រោកឡើងពីយល់សប្ដិទៅអាប្អូន!»

ជូរចត់....

ព្រោះខ្ញុំមិនឆ្លើយ តែគេដឹងថាខ្ញុំអាន គេសរសេរមកទៀត «ស្នេហាគ្រាន់តែជាអារម្មណ៍ វាមិនមែនជាការពិតទេ! រីដាមិនចេះស្រឡាញ់អ្នកណាឡើយ! គេគ្រាន់តែតស៊ូនឹងជំងឺផ្លូវចិត្តទទេស្អាតរបស់គេ! ឯងគ្រាន់តែជាការវង្វេងមួយដែលគេមិនចាំទេ ថាគេកំពុងឆ្កួត! បន្តិចទៀតគេព្យាបាលជា គេនឹងចេញពីពិភពឆ្កួតនេះ!»

មិនដឹងពីពេលណាដែល....ខ្ញុំបែរមករកម៉ូតូហើយ ជិះ.....ជិះទៅណា? អត់ដឹងទេ! ទឹកភ្នែករបស់ខ្ញុំស្រក់ នៅក្នុងមួកសុវត្ថិភាពរបស់ខ្ញុំ គ្មានអ្នកណាដឹងឬបានឃើញឡើយ ព្រោះពិភពលោកនេះខ្ញុំឆ្កួតវង្វេងតែម្នាក់ឯង។

ខ្ញុំស្មានថា គ្រប់យ៉ាងនឹងល្អប្រសើរឡើង!

ភាពមិនស្មោះត្រង់គឺជារឿងមួយដែលបង្កការឈឺចាប់បំផុតសម្រាប់ខ្ញុំ។ តាំងពីខ្ញុំនៅក្មេង ម៉ាក់ដែលខ្ញុំចង់ឱប ដែលខ្ញុំត្រូវការបំផុតបានក្បត់គ្រួសារយើង គាត់ក្បត់ប្ដីហើយនិងកូនប្រុស ចោលមនសិកាទៅតាមបេះដូងរាយមាយសាវារបស់គាត់។

ការចាកចេញរបស់មនុស្សស្រីដែលផ្ដល់កំណើតឱ្យខ្ញុំ បន្សល់ទុកនូវការឈឺចាប់កំហឹងនិង អារម្មណ៍តូចចិត្ត អាប់អួរ។ វ័យកុមារដែលទទួលបានតែការចំអក បានបង្កើតនូវវ័យជំទង់មួយ ដែលអាប់អួរដោយអំពើហិង្សា ហើយខ្ញុំឈានទៅដល់ការវាយតប់គេម្ដងហើយម្ដងទៀតរហូត ដល់ត្រូវចំណាយពេលក្នុងពន្ធនាគារ។

ដោយដកដង្ហើមវែងៗ ខ្ញុំជូតទឹកភ្នែកនិងប្រាប់ខ្លួនឯងថា ខ្ញុំមានភាពថ្នឹកជំនាញនៅក្នុងការ ប្រឈមមុខនឹងការឈឺចាប់ ដែលពិភពលោកនេះបានទម្លាក់មកលើស្មាខ្ញុំ។

ខ្ញុំមានភាពថ្នឹកជំនាញនៅក្នុងការដោះស្រាយជាមួយពេលវេលាដ៏លំបាកៗបំផុតនៅក្នុង ជីវិតជាកូនកំព្រាម្ដាយ ប៉ុន្តែអារម្មណ៍បាត់បង់ពៅដែលស្លូតបូតរបស់ខ្ញុំ និងអារម្មណ៍រកឃើញ ប្រពន្ធអ្នកមានម្នាក់ដែលមានរូបរាងដូចជានាងប៉ុន្តែឈ្មោះថារីដា ហើយ....ជាមនុស្សបោក ប្រាស់....ផិតក្បត់ស្វាមី....ប្រតិកម្មដំបូងដែលរុញបុកបេះដូងរបស់ខ្ញុំ មិនត្រឹមតែកំហឹង ថែម ទាំងសោកសៅនិងចុងក្រោយអស់សង្ឃឹម។

ខ្ញុំឈប់ម៉ូតូហើយអង្គុយម្នាក់ឯង...ហេតុអ្វីបានជាខ្ញុំមកដល់ទីនេះ កន្លែងដែលពួកយើងជួប គ្នាដំបូង?

ក៏ជាកន្លែងដែលយើងតែងតែជួបគ្នារហូតមក។

ដៃរបស់មនុស្សនោះនៅលើចង្កេះនាង ទង្វើអសីលធម៌នៅក្រៅផ្ទះ ក្បត់ក្នុងចំណង អាពាហ៍ពិពាហ៍របស់នាង គឺជាការប្រមាថមកលើមនោសញ្ចេតនាមួយដែលខ្ញុំធ្លាប់គិតថា មាន ភាពបរិសុទ្ធ។

ខ្ញុំមិនដែលត្រូវការកូនស្រីអ្នកមាន ខ្ញុំមិនដែលចង់បានអ្វីពីអ្នកទាំងអស់ ក្រៅពីភាពស្មោះ ត្រង់។ ខ្ញុំគ្រាន់តែត្រូវការមនុស្សស្រីម្នាក់ដែលមានភាពស្មោះត្រង់ មិនដូចម៉ាក់ខ្ញុំកាលពីអតីត កាល។

ទូរសព្ទខ្ញុំលោតសារទៀត។

ខ្ញុំលើកដៃជូតទឹកភ្នែក។ កូនប្រុសម្នាក់ធ្លាក់ខ្លួនអង្គុយយំ គឺបង្ហាញថា បេះដូងរបស់គេឈឺជាងអ្វីដែលអ្នកគ្រប់គ្នាអាចមើលឃើញឬស្មានដឹង។

«បងនៅឯណា?»

នាងទើបនឹងនៅជាមួយប្ដី ឆ្លៀតផ្ញើសារមកខ្ញុំបានទៀត? ស្រីអាសិរ្ពិសមិនទាន់ដឹងផងទេថា ខ្ញុំដឹងរឿងគ្រប់យ៉ាងហើយ។

ខ្ញុំងាកមុខចេញ....ចង់ស្រែកដាក់អ្នកណាម្នាក់ដែលដើរកាត់ទីនេះ ថែមចង់ស្រែកដាក់ខ្លួនឯង ចង់បួងដៃ ពន្លែងកណ្ដាប់ទៅលើដើមឈើឬអ្វីក៏ដោយ ដើម្បីឱ្យការឈឺចាប់នៅកន្លែងនោះជួយស្រាយទម្លាយចោលទៅនូវសេចក្ដីឈឺចាប់ តឹងណែនយ៉ាងខ្លោចផ្សារធ្ងន់កណ្ដុកក្នុងបេះដូងមួយនេះ។

....អត់ទេ....ក្រោកឡើងវណ្ណឌី!

ខ្ញុំចង់ឈប់គិត!

ខ្ញុំជាមនុស្សប្រុសម្នាក់ ត្រូវគេបោកសំណាងហើយប៉ះចំប្ដីគេជាមនុស្សអហិង្សា គេគ្រាន់តែព្រមានខ្ញុំ ចុះប្រសិនបើមានរឿងលើសពីនេះ តើខ្ញុំដោះស្រាយយ៉ាងណា?

ហោចណាស់ក៏ល្អ ខ្ញុំដឹងខ្លួនទាន់ពេលវេលាមែនទេ?

ខ្ញុំចាប់ម៉ូតូហើយត្រលប់ទៅបន្ទប់ជួលវិញ។

ជំហានបន្ទាប់ គឺសូម្បីតែមនុស្សស្រីឈ្មោះពៅក៏ខ្ញុំលែងចង់ឮដែរ កុំថាតែទូរសព្ទរបស់គេត្រូវបានប្លុកលេខ លុបអ្វីៗទាំងអស់ទាក់ទិននឹងគេចេញ។

ទោះបីយ៉ាងណា ពពកខ្មៅកំពុងបិទបាំងជីវិតខ្ញុំ.....ថ្ងៃណាក៏ងងឹត ពេលណាក៏បេះដូងខ្ញុំឮសូរមកតែពាក្យខ្លីៗថា«បោកប្រាស់»។

ខ្ញុំចាកចេញពីក្រុងភ្នំពេញប៉ុន្មានថ្ងៃ ទៅនៅផ្ទះប៉ាខ្ញុំជាមួយភរិយាក្រោយគាត់ជាយខេត្តកណ្ដាល។ គាត់ជាសាស្ត្រាចារ្យ តែដោយជីវិតគ្រួសារមិនគប្បី ជីវិតរងអាម៉ាស់ច្រើន ប្រពន្ធរត់ចោល កូនប្រុសដើរលេងហិង្សា គាត់បានចេញពីទីក្រុងមករស់នៅចិញ្ចឹមទាស្ងប់ស្ងាត់ពីអតីតកាលដែលមិនដឹងថា បានកម្ទេចបេះដូងគាត់កម្រិតណាទេ។

អង្គុយសម្លឹងហ្វូងសត្វ ហេតុអីបានខ្ញុំត្រូវដើរតាមលំនាំរបស់គាត់? ហេតុអីខ្ញុំត្រូវបំបែកបំបាក់គ្រួសារគេ? ខ្ញុំរស់នៅទីនោះបានបីថ្ងៃ

ព្រឹកមួយ....

«អាឪ មិត្តភក្តិមករក!»

ខ្ញុំកំពុងតែជម្រះស្មៅប្រុងថា នឹងជួយឱ្យចំណីសត្វជំនួសឪពុកខ្ញុំខ្លះ ងាកទៅខ្ញុំឃើញជាយសំពត់បក់រវិច នៅចម្ងាយប្រមាណជា២០ម៉ែត្រពីទីនេះ។

បេះដូងរបស់ខ្ញុំដូចចង់ស្ពឹកឈប់លោត...កំភួនជើងស្រឡូនដែលខ្ញុំចង់បាន....ឫកពារម្សៀទមរបស់គេ ដែលបានខាបយកវិញ្ញាណខ្ញុំ ពេលនេះនៅច្បាស់នឹងមុខខ្ញុំ។

លើកនេះគេជិះឡានមក ជាឡានដ៏ទំនើបចតមិនឆ្ងាយប៉ុន្មានពីកន្លែងគេឈរទេ។

ខ្ញុំនិងគេ នៅលើភ្លឺស្រែម្ខាងម្នាក់។

គេសម្លឹងមកខ្ញុំដែលបាំងនៅចំកណ្តាលដោយហ្វូងទាដ៏ធំឆ្លងកាត់។

គ្រាន់បើណាស់ មនុស្សមានវិបល្លាសដូចគេអាចរកផ្ទះខ្ញុំឃើញ? ការឃើចាប់ទាំងប៉ុន្មានដែលសង្កត់ខ្ញុំប៉ុន្មានថ្ងៃប៉ុន្មានមកនេះ និយាយគ្នាឱ្យអស់ម្តងក៏ល្អដែរ។

ខ្ញុំដើរមួយៗទៅដូចមនុស្សគ្មានវិញ្ញាណ។ សំឡេងគេលាន់មកតាមខ្យល់ពេលខ្ញុំទៅប្រឈមពីរម៉ែត្រពីមុខគេ។

«ប្រាប់បានទេ? ហេតុអីបានជាបងគេចពីខ្ញុំ! ឈប់លើកទូរសព្ទ ឈប់តបសារ ហើយឥឡូវខលអត់ចូល?!»

ខ្ញុំលើកចិញ្ចើមធ្វើមុខអស់សំណើចហើយសួរបកវិញ៖

«ខល? ខលខ្ញុំមែន? ខលធ្វើអី?»

គេទីទើរធ្វើមុខស្លូតៗ ភ្នែកក្រឡង់ៗសម្លឹងខ្ញុំ។ ធ្វើដូចជាគេនេះនឹកខ្ញុំខ្លាំងណាស់ ហើយគេកំពុងត្រូវការខ្ញុំ។ ចិត្តខ្ញុំវិញ ឃើញសភាពរបស់គេ ខ្ញុំកាន់តែផ្ទុះសៅហ្មង។

«ម៉េចបានជា....?»

គេនិយាយយឺតៗខ្សាវៗ....តែខ្ញុំធុញណាស់! ខ្ញុំធុញនឹងដេកនឹកទឹកមុខស្លូតៗរបស់គេ....ខ្ញុំធុញនឹងការឱបជាប់យ៉ាងមុតនូវអារុំធស្នេហារវាងខ្ញុំហើយនិងគេ វាឈឺពេកណាស់សម្រាប់ឱ្យខ្ញុំទ្រាំ....

«បាន!» ខ្ញុំរាដៃបិទភ្នែកដកដង្ហើមវែងហើយនិយាយបន្ត «បានហើយ ចាន់ រីដា! អ្នកស្រីចាន់ រីដា!»

គេហាក់ទន់ជើងដែលត្រូវខ្ញុំហៅឈ្មោះពិតគេទាំងនាមទាំងត្រកូល។ គេរង្គើប្រាណ ទឹកមុខស្លេក ទឹកភ្នែករលោង។ ខ្ញុំខាំមាត់ប្រឈមទាំងទឹកភ្នែកខ្ញុំខះរីងក្នុងជម្រៅបេះដូងមួយនេះ.... អតីតអ្នកទោសដែលមានបេះដូងស្មោះម្នាក់នេះ ចាប់កំណើតឡើងជាមួយមនុស្សក្បត់ហើយវិលមកស្រឡាញ់មនុស្សក្បត់ទៀត....

«អ្នកស្រីគិតថាខ្ញុំនេះហ្អី ទៅស្រឡាញ់ស្រីមានប្ដីហើយ? អ្ហះ? មើលខ្លួនឯងក្នុងកញ្ចក់អត់? ខ្ញុំនេះទៅស្រឡាញ់ប្រពន្ធអ្នកដទៃ? ខ្ញុំឱបកើតដែរ មនុស្សស្រីដែលរៀបការរួច? ក្រមុំៗងាប់អស់មែន?»

គេនៅគាំងជាមួយសំឡេងឮៗរបស់ខ្ញុំ....ហើយដូចខ្ញុំស្មាន...មិនយូរប៉ុន្មានគេក៏ស្រក់ទឹកភ្នែកស្ងប់ស្ងាត់តាមចរិតរបស់គេ។

តំណក់ទឹកភ្នែកនីមួយៗនិងរបៀបឈរខ្សោយៗដែលញ៉ាំងឱ្យបេះដូងខ្ញុំរហែកខ្ទេចខ្ទី។

វាជាការឈឺចាប់លាយបញ្ចូលគ្នា រវាងការបាត់បង់ខ្លួនឯង និងបាត់បង់គេនៅក្នុងអន្លង់ស្នេហាគ្មានតម្លៃមួយ។

គេក៏ឈឺខ្លាំង ទោះបីគេដឹងថាយើងទាំងពីរនឹងមានថ្ងៃនេះ....ចុះទម្រាំខ្ញុំដែលមោយរហូតមក តើខ្ញុំមានអារម្មណ៍បែបណា? អ្នកណាយល់ពីភាពខ្លោចផ្សាដែលខ្ញុំតែងតែផ្សារភ្ជាប់អារម្មណ៍របស់ខ្ញុំទៅជាមួយគេ តាំងពីថ្ងៃដែលយើងចួបគ្នាដំបូង....។

សម្ដីប្ដីគេ «ស្នេហាគ្រាន់តែជាអារម្មណ៍ វាមិនមែនជាការពិតទេ! រីដាមិនចេះស្រឡាញ់អ្នកណាឡើយ! នាងគ្រាន់តែតស៊ូនឹងជំងឺផ្លូវចិត្តទទេស្អាតរបស់នាង!»

ដូច្នេះហេតុអីខ្ញុំត្រូវជឿលើអារម្មណ៍នេះ....

គេវាសសក់ហើយជូតទឹកភ្នែក។ ឈុតខោអាវដ៏ថ្លៃថ្នូររបស់គេ រំឭកមកវិញដូចដំបងសំពង ខ្ញុំ សម្ដីប្ដីសង្ហារបស់គេ «ហើយ....ទោះជាគេមិនទាន់រៀបការឬទំនេរ ក៏ប្អូនឯងនេះនឹងគេ មេឃ ហើយនិងដី! គ្មានថ្ងៃចូលគ្នាចុះទេប្អូនប្រុស!»

ខ្ញុំខាំមាត់ សម្លឹងចំៗភ្នែកនាងដែលសែនល្ងល្ងេវសម្លឹងមើលមកខ្ញុំ ប៉ុន្តែនៅចំពោះមុខការពិតដ៏ឃោរឃៅមួយដែលខ្ញុំត្រូវតែបកអាក្រាត មិនអាចប្រើអារម្មណ៍មកដឹកនាំជីវិតបាន....ខ្ញុំចាំបាច់ត្រូវធ្វើ....

«ខ្ញុំដាល់អ្នកដទៃដើរចូលគុក ព្រោះតែគេមើលងាយប៉ាខ្ញុំ! គេដៀលខ្ញុំថា មានម៉ាក់ផិតប្ដីរត់ចោលកូន! ឮអត់អ្នកស្រី? ខ្ញុំស្អប់ណាស់ ខ្ញុំស្អប់បំផុតពួកមនុស្សកុហកបោកប្រាស់ ខ្ញុំស្អប់មនុស្សស្រីផិតប្ដី!»

ដើរកាត់ពីមុខនាង ខ្ញុំឆ្លៀតជូនពាក្យចុងក្រោយ៖

«អាម៉ាស់ជំនួស!»

ជាការពិត ខ្ញុំស្អប់មនុស្សស្រីអសីលធម៌ អនាចារ ខ្ញុំស្អប់ណាស់មនុស្សតណ្ហាក្រាស់ នៅទីនេះគ្មានតណ្ហាលេងសើចទុកលក់ឱ្យស្រីអ្នកមានតុកស៊ិកដូចពួកនេះទេ។

«យប់នោះ អូនរវល់ឈ្លោះលែងលះជាមួយគេ!»

នាងនិយាយពីក្រោយខ្នងខ្ញុំ ខ្ញុំរឹតតែបង្កើនល្បឿន សំឡេងនាងនៅតែលាន់មក៖

«អូនមិនបានក្បត់ តែអូនមិនដែលស្រឡាញ់គេទេ!»

ខ្ញុំខាំមាត់បិទភ្នែក។

ចិត្តខ្ញុំលេចឡើងនូវមនុស្សស្រីពីរនាក់។ មួយគឺគេ ជាព្រាយមុខស្លូត ទីពីរម៉ាក់ខ្ញុំ ជាមនុស្សស្រីដែលមិនស្រឡាញ់កូនរើសយកមនុស្សប្រុស។

ខ្ញុំមិនងាកក្រោយទេ!

បកទៅធ្វើការងារវិញ ខ្ញុំស្មានថាចប់ហើយ ស្រាប់តែ...

«ប្អូនមិនបាច់ធ្វើការនេះទេ លុយកក់ទាំងអស់យកចុះ យើងចប់ជាមួយគ្នាត្រឹមនេះព្រោះដៃគូយើងគេប្រគល់អ្នកឌីហ្សាញបរទេសមកឱ្យ គេមិនទទួលការឌីហ្សាញរបស់ប្អូនទេ!»

ខ្ញុំងាកទៅឃើញដើងជននោះអង្គុយគងអន្ទាក់ខ្លា។

ស្គាល់ពេកហើយ!

ខ្ញុំលេងនិយាយជាមួយម្នាក់នេះ ដោយដើរសំដៅទៅ។ ឈ្មោះតារានេះ ប្ដីរបស់រីដា។ គេមករករឿងទាល់តែភ្ញៀវបញ្ឈប់កុងត្រាជាមួយខ្ញុំទៀត?

ខ្ញុំឈរនៅពីមុខគេជាមួយទឹកមុខស្មើ...ព្រោះខ្ញុំគ្មានរឿងអ្វីខ្លាច ខ្ញុំមិនបានធ្វើអ្វីខុសទាំងអស់។ តាមពិតខ្ញុំព្យាយាមគេចពីនាងហើយ ជននេះនៅតែតាមរករឿងសូម្បីអាជីពខ្ញុំ។

«ទំនេរពេក?»

ខ្ញុំសួរទៅកាន់ទឹកមុខសុភាពបុរសរបស់អ្នកដែលអង្គុយខែងរ៉ែង។

«ឬលុយច្រើនពេកអផ្សុក កើតរោគចិត្តថែមម្នាក់ទៀតហើយ?»

ខ្ញុំនិយាយបែបនេះ ខាងភ្ញៀវស្ទុះចូលមករកបណ្ដេញឃាត់ខ្ញុំ តែខ្ញុំវាសដៃចេញ។ ប្ដីនាងក៏ក្រោកមកហើយរាដៃធ្វើដូចជាគេអាចដោះស្រាយជាមួយខ្ញុំបាន។

គេឱ្យសញ្ញាអ្នកនោះចេញទៅហើយបិទទ្វារOfficeវិញដោយខ្លួនគេ។

«ខ្ញុំចង់ឯងចាកចេញពីភរិយារបស់ខ្ញុំ!»

ខ្ញុំសើចក្អាកក្អាយ តែចិត្តខ្ញុំយំព្រោះពាក្យ«ភរិយាខ្ញុំ»នេះ ស្ដាប់ឡើង«ឈឺ»ជាសម្ងាត់។

«ស្ដាប់ លោកតារា! សហគ្រិនជោគជ័យ! ឮឱ្យបានច្បាស់ ខ្ញុំមិនដែលស្រឡាញ់ប្រពន្ធរបស់អ្នកណានោះទេ! ទាន់? ស្រីដែលខ្ញុំធ្លាប់ស្រឡាញ់នោះឈ្មោះពៅ ជាស្រីក្រមុំ គ្មានប្ដីនោះទេ ឥឡូវនេះគេស្លាប់បាត់ហើយ! ខ្ញុំមិនជំពាក់អីអ្នកណា ហើយក៏ខ្ញុំមិនបាច់ឱ្យអ្នកណាមកទាររបស់ដែរឮ! ជាជាងចំណាយពេលវេលាដើរកកូរខ្ញុំ ទៅរៀបចំខ្លួនប្រាណអង្គុយចាប់ប្រពន្ធរបស់ខ្លួនឱ្យគង់ទៅ!»

ខ្ញុំចាកចេញមកទាំងដឹងថា រឿងនាងតាមរកខ្ញុំនៅកន្លែងចិញ្ចឹមទា ជាមូលហេតុដែលគេលុបកុងត្រាខ្ញុំចោល។ គ្រប់យ៉ាងមិនយុត្តិធម៌ទេ សម្រាប់ការប្រឈមនឹងពួកមានលុយមានអំណាចដូចគេ ហើយខ្ញុំក៏មិនចង់តតាំងអ្វីដែរ។

បេះដូងនេះ....ឈឺឆ្អែតហើយ!

ដើម្បីចាកចេញពីរឿងដ៏ឈឺចាប់និងដ៏ស្មុគស្មាញថ្មីមួយនេះ ខ្ញុំសម្រេចចិត្តចាកចេញពីទឹកដីនេះមួយរយៈ ដាក់ពាក្យទៅធ្វើការនៅបរទេស ជាពលករឆ្លងដែន។

ខ្ញុំបានចាកចេញពីប្រទេសដែលខ្ញុំស្រឡាញ់ មកធ្វើការដូចគ្មានបេះដូង និងរស់នៅរងាឯកោ ដោយព្យាយាមមិនប្រើអារម្មណ៍អ្វីទាំងអស់។

ប្រសិនមានលុយច្រើនផ្ញើទៅប៉ាជារឿងល្អ។

ស្នេហា.....គ្រាន់តែជាអារម្មណ៍ ពាក្យនេះនៅតែជាអ្វីមួយដែលត្រជាក់ និងមុតយ៉ាងសាហាវ យ៉ាងជ្រៅក្នុងបេះដូងខ្ញុំមកទល់ឥឡូវ។

ជាង១០ខែមកហើយ...យប់នេះមិនដឹងហេតុអ្វីខ្ញុំដែលចិត្តប្រែជារសាប់ចម្លែក ដៃចុចរាវចូលទៅក្នុងគណនីបណ្តាញសង្គមដែលខ្ញុំអត់បោះបង់ចោល អត់រវល់ជាយូរមកហើយ។

ពិតជាបានឃើញមនុស្សស្រីម្នាក់ ដាក់ឈ្មោះខ្លួនឯងថា«ពៅ»។

មនុស្សស្រីដែលពីមុនមកមិនធ្លាប់និយមលេងទូរសព្ទ គេចាប់ផ្តើមលេងបណ្តាញសង្គមក្រោយពេលមានខ្ញុំ ខ្ញុំស្រាប់តែកើតរោគរឿងចាស់រើ ហើយចង់ដឹងថា ជាង១០ខែមកនេះ គេបោកប្រុសណាទៀតហើយ?

«យប់នេះគ្រប់យ៉ាងស្ងប់ស្ងាត់ណាស់ មិនខុសនឹងចិត្តដ៏ស្ងប់របស់ខ្ញុំទេ! ខ្ញុំស្រាប់តែចង់សរសេរទៅកាន់មនុស្សម្នាក់ដែលខ្ញុំស្រឡាញ់! រយៈពេលយូរប៉ុនណាក៏ដោយ អ្វីទាំងអស់នេះមិនស្តាយក្រោយទេ ខ្ញុំអាចរស់នៅម្នាក់ឯងបានហើយ ខ្ញុំស្គាល់ពីអត្ថន័យនៃការរស់នៅ ដែលត្រូវឈឺចាប់ ដោយចងចាំរូបគេម្នាក់ ថាបេះដូងនេះឈឺយ៉ាងណា តែយ៉ាងហោចណាស់ ក៏មានជីវិតមិនទទេស្អាតដូចពីមុន! អរគុណដែលអ្នកបានកម្ចាត់ភាពទន់ខ្សោយទាំងអស់ពីជីវិតស្រីម្នាក់នេះ ឱ្យខ្ញុំចេះរឹងមាំដើម្បីចងចាំរឿងខ្ញុំនិងគេ! អត្ថន័យនៃបណ្តាថ្ងៃនីមួយៗ ទោះបីជាត្រូវឈឺចាប់ប៉ុនណាក៏ដោយ យ៉ាងហោចណាស់ខ្ញុំចង់ចងចាំស្នេហា ស្អាតស្អំនិងភាពស្មោះត្រង់ ដែលខ្ញុំមិនដែលរកបាននៅក្នុងជីវិតនេះ! អ្នកជាមនុស្សប្រុសដែលខ្ញុំស្រឡាញ់ហើយមិនដែលស្តាយក្រោយទេ វណ្ណឌី!»

គេហៅខ្ញុំបែបនេះ Mention ខ្ញុំចំៗ។

ពេញមួយយប់ ខ្ញុំឆ្កួតចិត្ត....ខ្ញុំស្រែកឃ្លានតាមដានអ្វីៗទាំងអស់ដែលគេបានសរសេរនៅលើបណ្តាញសង្គមរវាងជាង១០ខែមកនេះ។

បន្ទាប់មកខ្ញុំឃើញព័ត៌មានពីការលែងលះរបស់គេ។

ការតាមរករឿងរបស់អតីតស្វាមីគេ ឈ្លោះគ្នាជាមួយប៉ាគេនៅទីសាធារណៈ ហើយចុងក្រោយគ្រួសារគេបានប្ដឹងលោកតារាដែលធ្វើទុក្ខបុកម្នេញលើរាងកាយគេ ទាំងអស់សិទ្ធិក្នុងចំណងអាពាហ៍ពិពាហ៍។

ប៉ុន្មានថ្ងៃក្រោយមកទៀត ខ្ញុំបានទទួលដំណឹងថា គេចាកចេញទៅប្រទេសជប៉ុនដើម្បីសិក្សាបន្តច្រើនជាងបីខែមកហើយ។

សួរអ្នកបើកឡានគេពីមុន គាត់ប្រាប់ថា គេរឹងមាំច្រើនខុសពីមុនទាំងស្រុង អាចរស់នៅម្នាក់ឯងបាន។

ហោចណាស់ មានអារម្មណ៍ថាសប្បាយចិត្ត។

សង្ឃឹមថា គេរកឃើញអ្នកណាម្នាក់សមគ្នាជាមួយគេ ហើយគេក៏សប្បាយចិត្តក្នុងការផ្ដើមជីវិតថ្មីជាមួយអ្នកនោះ។ សម្ដីអតីតស្វាមីរបស់គេខ្ញុំនៅចងចាំ បើទោះបីជារីដាជាស្រីក្រមុំ ឬគ្មានអ្នកណា ក៏ខ្ញុំនឹងគេមិនអាចឈោងដល់គ្នាដែរ។ ការទទួលយកការពិតគឺជាអ្វីដែលខ្ញុំត្រូវតែធ្វើពី ព្រោះថាយើងមិនអាចរត់នៅក្នុងភាពសប្បាយ ឬក៏ក្នុងមនោសញ្ចេតនាដែលមានលន្លង់លន្លោចតែក្នុងប្រលោមលោកនោះទេ។

ខ្ញុំសន្យាថាឈប់ឃុំខ្លួនឯងនៅនឹងអតីតកាលជាមួយគេ ហើយបន្តដំណើរជីវិតទៅមុខទៀត តើខ្ញុំអាចរកឃើញមនុស្សស្រីមកដាក់ជំនួសគេក្នុងបេះដូងប្រេះរហែកមួយនេះដែរ?

ច្រើនខែមកទៀត អ្វីម្យ៉ាងនៅតែឈឺៗត្រូវបានដោតជាប់ស្រមោលនៅក្នុងប្រអប់បេះដូងមួយនេះ។

ខ្ញុំត្រាច់ចរទៅគ្រប់ទីកន្លែង នៅសេអ៊ូលឬក្រុងដទៃ ខ្ញុំពិតជាឯកោនិងរងាឡើងៗ។

ធម្មតា...ខ្ញុំគួរតែចៀសវាងការតាមដានអំពីមនុស្សដែលបេះដូងខ្ញុំទាមទារ។ មិនថាការចួបដោយផ្ទាល់ឬតាមអនឡាញ កន្លងមកខ្ញុំបានធ្វើរួចហើយ តែម្ដេចប៉ុន្មានថ្ងៃនេះមានអារម្មណ៍ចម្លែកចេះតែរពឹសដៃចង់ឃើញគេ ថាឥឡូវនេះគេធាត់ឬស្គម។

ហើយខ្ញុំក៏ចង់ដឹងដូចគ្នាថា តើគេនៅជប៉ុនគេបានជួបអ្នកណាម្នាក់ឬនៅ? អ្នកណាម្នាក់ទៅនៅជាមួយគេ?

សាជាថ្មីខ្ញុំទទួលដំណឹងថាគ្រួសាររបស់គេបានក្ស័យធន ដោយសារតែការប្រកួតប្រជែងសងសឹកគ្នារវាងគ្រួសារខាងអតីតប្តីរបស់គេនិងឪពុករបស់គេ ហើយពេលនេះប៉ាឈឺធ្ងន់ដោយសារតែបាត់បង់លុយកាក់ទ្រព្យសម្បត្តិ។

មួយអាទិត្យក្រោយមក ពូសូហ្វ័រដដែលបានឃែតមកថា ប៉ាគេស្លាប់ ហើយគេកំពុងតែខូចចិត្តម្នាក់ឯងតាមរបៀបជាកូនទោលនិងគ្មានញាតិច្រើន។ ខ្ញុំចាប់ផ្តើមទិញសំបុត្រទៅកាន់ប្រទេសជប៉ុន។

ខ្ញុំមិនដឹងថា មានអ្វីជាហេតុផលសំអាងដែលខ្ញុំសម្រេចចិត្តបែបនេះទេ តែថាបេះដូងរបស់ខ្ញុំនៅមានគេ ហើយមានតែគេម្នាក់គត់ទោះខ្ញុំខំសម្លឹងមើលស្រីណាផ្សេងក៏នៅតែមិនអាចបំភ្លេចកែវភ្នែកទុក្ខព្រួយរបស់គេ។

ពូនោះបានប្រាប់ខ្ញុំថា គេកម្សត់ជាងជីវិតខ្ញុំទៅទៀត។

ចាប់តាំងពីគ្មានម៉ាក់ គេត្រូវគ្មានទាំងមិត្តភក្តិ និងគ្មានអ្នកណាទុកចិត្តបានទាំងអស់។ គេលែងញញឹមយូរហើយ រហូតដល់គេចួបខ្ញុំ។

គេជាមនុស្សស្រីស្ងឹកៗ មិនចង់ស្តី មិនចង់ស្តាប់ ខ្ជិលគិត និងខ្ជិលស្វែងយល់ពីអ្វីគ្រប់យ៉ាង។ នៅក្រោយពេលរៀបការទៀត អ្នកផ្ទះបារម្ភគេខ្លាំង។ គេរឹតតែលែងមានប្រតិកម្មដោយអារម្មណ៍នៅពេលគេត្រូវប្តីគេផ្ទក់នៅជាមួយនាយប់ស្រវឹងស្រាមួយ ហើយកូនគេក៏រលូត។

រីជាមិនដែលផ្សារភ្ជាប់ខ្លួនឯងទៅនឹងពិភពលោកជុំវិញនេះទៀតទេ។ ប៉ានាងតែងនាំនាងទៅរកពេទ្យចិត្តសាស្ត្រ តែមិនអាចកែខៃអ្វីឱ្យប្រសើឡើងទាំងអស់....ពូនោះជាមនុស្សស្មោះត្រង់និងយល់ពីសភាពរបស់នាង គាត់គិតថា ខ្ញុំតែម្នាក់គត់ជាមនុស្សសម្រាប់នាង....ដែលនាងអាចញញឹមវិញបាន។

លែងគិតអ្វីទាំងអស់ខ្ញុំសម្រេចចិត្តទៅរកគេ និងសុំទោសគេ។ ការប្រឈមមុខរបស់គេចំពោះពិភពលោកនេះឡើងវិញ គេប្រឈមនឹងការឈឺចាប់បាន ព្រោះតែខ្ញុំ ព្រោះតែគេចង់ចងចាំខ្ញុំ។

យប់នេះអាកាសធាតុត្រជាក់ខ្លាំង។

ព្រិលធ្លាក់រពុយនៅពីមុខអន្តេវាសិកដ្ឋានមហាវិទ្យាល័យ Akita។ គេប្រហែលជាគិតថា ព្រិលភ្នែកឬក៏ស្រមៃ ពេលឃើញខ្ញុំ ប៉ុន្តែគេនៅតែដើរចូលមក ទីបំផុតចម្ងាយប្រហែល១០ម៉ែត្រ ពីគ្នា គេរត់មក....។

ជិតពីរឆ្នាំមកនេះ គេនៅតែមានសភាពដូចថ្ងៃចួបគ្នាដំបូង....គេសម្លឹងឃើញខ្ញុំច្បាស់ក៏ឈប់ ជើងប្រមាណជាបីម៉ែត្រពីគ្នា។

ឃើញគេ...រលីងរលោងនិយាយតិចៗ «ខ្ញុំរស់នៅម្នាក់ឯងបានហើយ!» ហើយគេឈប់ និយាយ នៅតែបន្តិចគេនឹងសួរខ្ញុំថា «មកធ្វើអី?» តែ...ខ្ញុំមិនចង់ចាំទេ....ខ្ញុំដើរចូលទៅជាមួយ ទឹកមុខនឹករលឹក។ ពិភពលោកនេះ ដូចជាគ្រប់គ្នារលាយទៅក្រោមព្រិលអស់ហើយ មានតែខ្ញុំ ហើយនិងគេប៉ុណ្ណោះ។

ខ្ញុំគួរប្រាប់គេទេថា បេះដូងនេះនៅមានគេ ប៉ុន្តែបេះដូងពេលនេះជាមួយពេលមុនខុសគ្នា.... ពីមុនខ្ញុំជឿថាគ្រប់យ៉ាងដែលគេឱ្យមកគឺជាការស្រមៃ គឺជាអារម្មណ៍....មិនមែនជាការពិត អារម្មណ៍អាចប្តូរ អាចរលាយបាត់តាមពេលវេលា សល់តែការពិតដែលអន្ទោលឈឺចាប់ ប៉ុន្តែ ពេលនេះ.....គេអាចធ្វើអ្វីៗជាការពិត.....ខ្ញុំឈានដល់ពីមុខគេ ហានិយាយជាមួយដង្ហើម ចំហាយកកៈ

«ឈ្មោះវណ្ណឌី ជាកម្មករម្នាក់! រកស៊ីលក់កម្លាំងនៅប្រទេសកូរ៉េ! ពេលនេះ ខ្ញុំចង់សុំស្រឡាញ់ អ្នកនាង រីដា មកពីគ្រួសារត្រកូលអភិជន ហើយចង់រៀបការជាមួយគេ ថែរក្សាគេអស់មួយជីវិត ....ប្រាប់ខ្ញុំផង ទៅរួចដែរទេ?»

នាងយំហើយឈរធ្មឹង។ ដៃទាំងពីរជូតទឹកភ្នែកញាប់ៗ។

មិនថាគេជាពៅឬក៏រីដា ឬអ្នកណាទេ ស្នេហារបស់គេចំពោះខ្ញុំតាំងពីដំបូងគឺជាការពិត ជា ស្នេហាដំបូងក្នុងជីវិតគេ។

«ហើយមួយទៀត I am Sigle and you too»

ខ្ញុំនិយាយខ្សឹបៗខណៈគេនៅតែយំ។

ខ្ញុំនិយាយបន្ថែមៈ

«បើអូនប្រាប់មកថា ស្នេហាមួយនេះមិនទៅរួចទេ បងនឹងចាកចេញ!»

រីដានិយាយខ្លីៗ....តែវាមានន័យគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំជាមួយគេ....នេះហើយគឺជារឿងរបស់ខ្ញុំ។